សំណួរសួរញឹកញាប់អំពី SUN Bucks

កម្មវិធីអាហារូបត្ថម្ភរដូវក្តៅសម្រាប់កុមារ។ អត្ថប្រយោជន៍គ្រឿងឧបភោគបរិភោគដែលជួយរក្សាថាមពលដល់កូនៗរបស់អ្នកសម្រាប់រដូវក្តៅ!

តើខ្ញុំនឹងទទួលបានប៉ុន្មានពី SUN Bucks?

$120 សម្រាប់កូនក្នុងវ័យសិក្សាម្នាក់ៗដែលមានសិទ្ធិទទួលបាន។ វាគឺជាប្រាក់បើកតែម្តងគត់ ដែលអាចប្រើប្រាស់បានសម្រាប់ខែក្នុងរដូវក្តៅ។

តើខ្ញុំត្រូវប្រើប្រាស់ SUN Bucks យ៉ាងដូចម្តេច?

លុយអត្ថប្រយោជន៍ត្រូវបានដាក់បញ្ចូលទៅក្នុងកាត SUN Bucks។ គ្រួសារនីមួយៗនឹងទទួលបានកាតមួយសម្រាប់កូនទាំងអស់ដែលមានសិទ្ធិ។ SUN Bucks អាចប្រើប្រាស់បាននៅគ្រប់ទីកន្លែងដែលទទួលយក SNAP។

តើខ្ញុំត្រូវការកាតថ្មីរៀងរាល់ឆ្នាំដែរឬទេ?

បើអ្នកធ្លាប់មាន SUN Bucks ក្នុងឆ្នាំ 2025 ហើយបានបើកកាតរបស់អ្នករួច ហើយអ្នកអាចបន្តប្រើកាតដដែលនោះបាន! បើអ្នកទើបតែចូលរួមក្នុងកម្មវិធីនេះ ឬមិនទាន់បានបើកកាតរបស់អ្នកកាលពីឆ្នាំ 2025 នោះទេ យើងនឹងផ្ញើកាតថ្មីសម្រាប់ឆ្នាំ 2026 ជូនអ្នកដោយស្វ័យប្រវត្តិតាមប្រៃសណីយ៍។

តើត្រូវធ្វើដូចម្តេចបើខ្ញុំបាត់កាត SUN Bucks?

គ្មានបញ្ហា! អ្នកអាចស្នើសុំកាតថ្មីតាមវិធីពីរយ៉ាងៈ

ចូលគណនីរបស់អ្នកនៅលើគេហទំព័រ **DTAConnect.com**

ឬទាក់ទងទៅកាន់លេខទូរសព្ទទាន់ហេតុការណ៍របស់ SUN Bucks តាមលេខ **855-425-8770**

តើខ្ញុំមានរយៈពេលប៉ុន្មានដើម្បីចាយលុយ SUN Bucks របស់ខ្ញុំ?

លុយ SUN Bucks ត្រូវតែចាយក្នុងរយៈពេល **122 ថ្ងៃ** គិតចាប់ពីថ្ងៃដែលលុយអត្ថប្រយោជន៍ត្រូវបានដាក់បញ្ចូល បើមិនដូច្នោះទេ លុយនោះនឹងត្រូវបានកាត់យកវិញ។

ដាក់ពាក្យសុំ ឬស្វែងយល់បន្ថែមនៅលើគេហទំព័រ mass.gov/SUNBucks

Department of Transitional Assistance

MASSACHUSETTS Department of Elementary and Secondary Education